# «យុទ្ធសាស្រ្តសន្តិសុខថ្មីរបស់ជប៉ុន»

*ដោយ៖ លឹម សុវណ្ណរិទ្ធ រាជបណ្ឌិត្យសភាកម្ពុជា*
*ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣*



ក្នុងអតីតកាល ជប៉ុនគឺជាប្រទេសចក្រពត្តិនិយមមួយ ដែលឈ្លានពានបណ្តាប្រទេសជិតខាងដើម្បីមហិច្ឆតាកសាងប្រទេសរបស់ខ្លួនជាមហាអំណាចប្រកបដោយសក្តានុពល។ ដោយសារតែជប៉ុនជាប្រទេសដែលព័ទ្ធជុំវិញដោយសមុទ្រ និងពុំសូវសម្បូរធនធានធម្មជាតិ ជប៉ុនត្រូវស្វែងរកវត្ថុធាតុដើមពីខាងក្រៅ ដើម្បីបំពេញសក្តានុពលរីកចម្រើននៃសេដ្ឋកិច្ចនិងសង្គមរបស់ខ្លួន។ ហេតុនេះហើយ ជប៉ុនមានភាពចាំបាច់មិនអាចចៀសបានក្នុងការទាញយកធនធាននានាពីប្រទេសជិតខាង ពិសេសប្រទេសចិនដែលជាទឹកដីសម្បូរទៅដោយធនធានធម្មជាតិ។ ទោះជាយ៉ាងណា នយោបាយវាតទីនិយមរបស់ជប៉ុន ត្រូវបានបញ្ចប់នៅក្រោយសហរដ្ឋអាម៉េរិកបានលូកដៃចូលសង្គ្រាមលោកលើកទី២ និងបានបញ្ចប់សង្គ្រាមនេះតាមរយៈការទម្លាក់គ្រាប់បែកនុយក្លេអ៊ែរចំនួនពីរគ្រាប់ទៅលើទីក្រុងហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី។ នៅក្នុងសន្ធិសញ្ញាបញ្ចប់សង្គ្រាមលោកលើកទី២ដែលចុះហត្ថលេខាជាមួយនឹងសហរដ្ឋអាម៉េរិក មេដឹកនាំជប៉ុនបានយល់ព្រមចុះចាញ់ដោយឥតលក្ខខណ្ឌ និងបានប្រកាន់យករដ្ឋធម្មនុញ្ញសន្តិភាពតាមរយៈសម្ពាធពីសហរដ្ឋអាម៉េរិកដែលជាប្រទេសឈ្នះសង្គ្រាម ដោយចាប់តាំងពីពេលនោះមក ជប៉ុនមានត្រឹមតែកងស្វ័យការពារប៉ុណ្ណោះ ចំណែកឯសន្តិសុខជាតិរបស់ជប៉ុន ត្រូវបានធានាដោយផ្ទាល់ពីសំណាក់សហរដ្ឋអាម៉េរិក ដោយអាម៉េរិកបានដាក់មូលដ្ឋានកងទ័ពរបស់ខ្លួននៅលើទឹកដីជប៉ុនរហូតមកដល់បច្ចុប្បន្ន។

ទោះជាយ៉ាងណា ពិភពលោកទាំងមូលបានផ្លាស់ប្តូរជាបន្តបន្ទាប់ទាំងស្ថានភាពភូមិសាស្រ្តនយោបាយ ការវិវត្តសេដ្ឋកិច្ចនៃបណ្តាប្រទេស សម្ព័ន្ធភាព បញ្ហាប្រឈមខាងសន្តិសុខ និងវិបត្តិនៅក្នុងតំបន់នីមួយៗ។ ជប៉ុននិងអាម៉េរិកដែលធ្លាប់ជាគូបដិបក្ខនឹងគ្នាក្នុងសម័យសង្រ្គាមលោកបានក្លាយទៅជាសម្ព័ន្ធមិត្តដ៏សំខាន់ ហើយបានអភិវឌ្ឍប្រទេសក្លាយទៅជាមហាអំណាចសេដ្ឋកិច្ចពិភពលោកទីពីរ។ ក្រោយមក ចិនដែលបានងាកមកប្រកាន់យកនូវប្រព័ន្ធសេដ្ឋកិច្ចមូលធននិយម បានវិវឌ្ឍខ្លួនទៅជាមហាអំណាចសេដ្ឋកិច្ចពីរជំនួសជប៉ុនដែលជាសត្រូវប្រវត្តិសាស្ត្ររបស់ខ្លួន និងបានពង្រីកឥទ្ធិពលនយោបាយ និងយោធារបស់ខ្លួនក្លាយទៅជាគូប្រឈមចម្បងរបស់អាម៉េរិកក្នុងការដណ្តើមតំណែងមហាអំណាចពិភពលោក។ ចំណែកសហព័ន្ធរុស្ស៊ីដែលបានទទួលមរតកពីសហភាពសូវៀត នៅបន្តជាមហាអំណាចយោធាទីពីរ និងត្រូវបានបស្ចិមប្រទេសចាត់ទុកជាបញ្ហាប្រឈមខាងសន្តិសុខរបស់ខ្លួនជាបន្ត។ ងាកមកប្រទេសជាប់នឹងជប៉ុនវិញ កូរ៉េខាងជើងដែលបានកំណត់យកការអភិវឌ្ឍអាវុធនុយក្លេអ៊ែរជាខែលការពាររបបកុម្មុយនីស្តរបស់ខ្លួន ជានិច្ចកាលតែងតែចេញសារនយោបាយ និងសាកល្បងនុយក្លេអ៊ែរ ព្រមទាំងបាញ់មីស៊ីលគំរាមកំហែងសន្តិសុខនៅក្នុងតំបន់ ពិសេសទៅកាន់ជប៉ុន និងកូរ៉េខាងត្បូងដែលជាសម្ព័ន្ធមិត្តរបស់អាម៉េរិក។ បន្ថែមពីលើនេះ ស្ថានភាពសន្តិសុខក្នុងតំបន់ និងពិភពលោកទាំងមូលកាន់តែស្ថិតក្នុងការប្រឈមខ្លាំងថែមទៀត ដោយសារតែការឈ្លានពានរបស់រុស្ស៊ីទៅលើប្រទេសអ៊ុយក្រែន និងភាពតានតឹងនៅក្នុងសំណុំរឿងកោះតៃវ៉ាន់ ដែលចិនតែងតែចាត់ទុកកោះនេះជាដែនអធិបតេយ្យរបស់ខ្លួន។

ដោយមើលឃើញពីការគំរាមកំហែងសន្តិសុខក្នុងតំបន់ និងដោយមានការបើកភ្លើងខៀវពីសំណាក់សហរដ្ឋអាម៉េរិកផងនោះ រដ្ឋាភិបាលជប៉ុនដែលចុងក្រោយនេះ ក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី ហ្វូមីអូ គីស៊ីដា បានសម្រេចដាក់ចេញនូវយុទ្ធសាស្រ្តសន្តិសុខថ្មីរបស់ខ្លួន ដើម្បីពង្រឹងសមត្ថភាពការពារ និងការឆ្លើយតបរបស់ជប៉ុនទៅលើហេតុការណ៍នានាពាក់ព័ន្ធនឹងបញ្ហាសន្តិសុខដែលអាចកើតមានឡើងនៅក្នុងពេលអនាគតខាងមុខ។

យុទ្ធសាស្រ្តសន្តិសុខថ្មីរបស់ជប៉ុន ត្រូវបានគេមើលឃើញថា បានចាប់ផ្តើមដុះពន្លកនៅក្នុងអាណត្តិអតីតនាយករដ្ឋមន្ត្រីជប៉ុន លោក ហ្សិន ស៊ូអាបេ ដែលធ្លាប់បានលើកឡើងអំពីគោលបំណងក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញសន្តិភាពជប៉ុន ហើយជំហរនេះក៏ត្រូវបានប្រកាន់យកជាបន្តដោយមេដឹកនាំគណបក្សប្រជាធិបតេយ្យសេរី (LDP) ដែលឡើងមកកាន់អំណាចបន្តពីលោក ហ្សិន ស៊ូអាបេផងដែរ។ នាយករដ្ឋមន្ត្រីបច្ចុប្បន្ន ហ្វូមីអូ គីស៊ីដា ដែលបានបានចូលកាន់តំណែងនៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១ ក្រោយលាលែងតំណែងរបស់លោក ហ្សិន ស៊ូអាបេ និងបានទទួលជោគជ័យបន្ទាប់នៅក្នុងការបោះឆ្នោតនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២ ត្រូវប្រឈមនឹងបញ្ហាពីរ ដែលប្រជាជនជប៉ុនយកចិត្តទុកដាក់ខ្ពស់បំផុតគឺ បញ្ហាសេដ្ឋកិច្ច និងបញ្ហាសន្តិសុខជាតិ។ លទ្ធផលនៃការបោះឆ្នោតបានផ្តល់ឱ្យក្រុមចម្រុះដែលដឹកនាំដោយ គណបក្សប្រជាធិបតេយ្យសេរី (LDP) របស់លោក ហ្វូមីអូ គីស៊ីដា

និងគណបក្សប្រឆាំងចំនួនពីរ ដែលបើកចំហរដើម្បីធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញសន្តិភាពរបស់ជប៉ុន ដែលមានសំឡេងភាគច្រើន(២/៣) នៅក្នុងសភាជាន់ខ្ពស់។

នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២ ជប៉ុនបានកែសម្រួលយុទ្ធសាស្ត្រការពារជាតិរបស់ខ្លួន ដោយបានអនុម័តឯកសារចំនួន៣ ស្តីពីការបង្កើនសមត្ថភាពការពារសន្តិសុខជាតិជប៉ុន តាមរយៈការបង្កើនថវិកាក្នុងវិស័យយោធា នៅក្នុងបរិបទភាពតានតឹងភូមិសាស្ត្រនៅក្នុងតំបន់។ យុទ្ធសាស្ត្រនេះ នឹងបង្កើនថវិកាចំណាយយោធាឱ្យកើនឡើងដល់២%នៃផលិតផលក្នុងស្រុកសរុបសម្រាប់រយៈពេល៥ឆ្នាំ ពីឆ្នាំ២០២៣ដល់ឆ្នាំ២០២៧។ នៅក្នុងការស្ទង់មតិរបស់ទូរទស្សន៍ NHK ជប៉ុន ប្រជាជនជប៉ុន៥៥% បានគាំទ្រការបង្កើនថវិកាយោធា ដោយកាត់បន្ថយការចំណាយសាធារណៈ ក្នុងនោះអ្នកផ្តល់សម្ភាសន៍ត្រឹមតែ២៩%ប៉ុណ្ណោះ បានជំទាស់នឹងបំណងនេះ។ នៅក្នុងយុទ្ធសាស្ត្រថ្មីរបស់ជប៉ុននេះ គឺផ្តោតជាសំខាន់ទៅលើ៖

១. បង្កើនសមត្ថភាពវាយប្រហារតបវិញទៅដល់ទីតាំងបាញ់មីស៊ីលរបស់សត្រូវ

២. ការអភិវឌ្ឍមីស៊ីលអ៊ីពែសូនិក (មីស៊ីលលឿនជាងសម្លេង៥ដង)

៣. ការបង្កើនវត្តមានកងទ័ពជប៉ុននៅភាគខាងត្បូង (កោះអូគីណាវ៉ា និងកោះនៅភាគនិរតី)

៤. ប្រមូលផ្តុំកងទ័ពជើងគោក ជើងទឹក និងកងទ័ពអាកាស ឱ្យស្ថិតក្រោមបញ្ជាការតែមួយ ដើម្បីឆ្លើយតបនឹងស្ថានការណ៍អាសន្នណាមួយ។

នៅក្នុងឯកសារនេះផងដែរ ជប៉ុនបានចង្អុលមុខចំៗថា ចិនគឺជាការគំរាមកំហែងសន្តិសុខដោយផ្ទាល់របស់ជប៉ុន។ ជាការពិតណាស់ ចិនដែលជាសត្រូវប្រវត្តិសាស្ត្រនឹងជប៉ុន ហើយបានពង្រីកឥទ្ធិពលយោធារបស់ខ្លួនជាបន្តបន្ទាប់ ព្រមទាំងកំពុងមានជម្លោះដែនអធិបតេយ្យជាមួយជប៉ុន នៅប្រជុំកោះ សេនកាគុ (ចិនហៅថា ទាវយូ) ផងដែរ។ ក្រៅពីនេះ ហេតុផលផ្សេងទៀតដែលជំរុញឱ្យជប៉ុនដាក់ចេញនូវយុទ្ធសាស្ត្រសន្តិសុខថ្មីនេះ រួមមាន សកម្មភាពរបស់ចិននៅក្នុងករណីសំណុំរឿងតៃវ៉ាន់ ការធ្វើតេស្តមីស៊ីលជាបន្តបន្ទាប់របស់កូរ៉េខាងជើងដែលចុងក្រោយនេះ បានបាញ់មីស៊ីលរំលងដែនអធិបតេយ្យរបស់ជប៉ុនថែមទៀតផង។ ជាមួយគ្នានេះដែរ ជប៉ុនដែលកន្លងមក អនុវត្តនូវរដ្ឋធម្មនុញ្ញសន្តិភាពនិយមដែលអាម៉េរិកបានចាប់បង្ខំក្នុងពេលចាញ់សង្គ្រាម និងដែលមានការធានាសន្តិសុខដោយផ្ទាល់ពីសំណាក់សហរដ្ឋអាម៉េរិក តាមរយៈការរក្សាមូលដ្ឋានទ័ពអាម៉េរិកនៅលើប្រទេសនេះ ត្រូវបានរដ្ឋបាលលោក ដូណាល់ត្រាំ លើកឡើងពីបំណងទាមទារថ្លៃការពារពីជប៉ុនទៅវិញ ដែលនេះក៏អាចជាហេតុផលមួយផ្សេងទៀត ដែលជំរុញឱ្យជប៉ុនពង្រឹងសមត្ថភាពយោធារបស់ខ្លួនផងដែរ នៅក្នុងទំនាក់ទំនងនយោបាយជាមួយមហាអំណាចអាម៉េរិក ដែលជានិច្ចកាលតែងតែផ្លាស់ប្តូរគោលនយោបាយទៅតាមមេដឹកនាំដែលឡើងមកកាន់អំណាចថ្មី។ ត្រង់ចំណុចនេះ ថ្នាក់ដឹកនាំជប៉ុនទំនងជាមើលឃើញថា ការបន្តដាក់បញ្ហាសន្តិសុខជាតិរបស់ខ្លួនទៅផ្ញើនៅលើជំហររបស់មេដឹកនាំថ្មី

របស់អាម៉េរិក ដែលតែងតែផ្លាស់ប្តូរផ្សេងៗគ្នាពីប្រធានាធិបតីមួយទៅប្រធានាធិបតីទៀតនោះ ជម្រើសដ៏ល្អគឺជប៉ុនគួរតែពង្រឹងសមត្ថភាពយោធារបស់ខ្លួន ដើម្បីអាចឆ្លើយតបជាបន្ទាន់ចំពោះការគំរាមកំហែងសន្តិសុខចំពោះមុខរបស់ខ្លួន ជាជាងរង់ចាំការសម្រេចពីទីក្រុងវ៉ាស៊ីងតោន ព្រោះបទពិសោធប្រវត្តិសាស្ត្របានបង្ហាញយ៉ាងច្បាស់ថា នៅជុំវិញជប៉ុន គឺសុទ្ធសឹងតែជាប្រទេសដែលជប៉ុនធ្លាប់ឈ្លានពានទាំងនៅមុនពេល និងក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ រាប់ចាប់តាំងពីចិន រុស្ស៊ី និងសូម្បីតែកូរ៉េខាងត្បូងដែលជាសម្ព័ន្ធមិត្តអាម៉េរិកដូចជប៉ុនក្តី។

ជារួម នៅចំពោះមុខស្ថានភាពនៃភូមិសាស្ត្រនយោបាយពិភពលោក និងការរីកចម្រើនបច្ចេកវិទ្យាយោធានាពេលបច្ចុប្បន្ន ការកំណត់យុទ្ធសាស្ត្រសន្តិសុខថ្មីរបស់ជប៉ុន គឺជាការចាំបាច់ណាស់សម្រាប់មហាអំណាចសេដ្ឋកិច្ចទី៣ពិភពលោកនេះ ដែលត្រូវប្រឈមមុខនឹងការគំរាមកំហែងខាងយោធា ពីសំណាក់ប្រទេសនៅជុំវិញខ្លួន ដែលសុទ្ធសឹងតែធ្លាប់មានប្រវត្តិជូរចត់ជាមួយជប៉ុន ពិសេសចិនដែលជាសត្រូវប្រវត្តិសាស្ត្រ ស្របពេលដែលតំបន់អាស៊ីប៉ាស៊ីហ្វិកទាំងមូលបានក្លាយទៅជាចំណុចក្តៅនៃការប្រកួតប្រជែងរបស់មហាអំណាចពិភពលោក ពិសេសរវាងចិន និងសហរដ្ឋអាម៉េរិកព្រមទាំងសម្ព័ន្ធមិត្ត។ ទោះជាយ៉ាងណា វាក៏ជាសញ្ញាដែលបង្ហាញអំពីការរត់ប្រណាំងសព្វាវុធកាន់តែស៊ីជម្រៅខ្លាំងទៅៗនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកទាំងមូល ដែលនាំទៅដល់ការប្រឈមគ្នាដ៏ផុយស្រួយផងដែរ៕




83

